# ការសំភាសន៍របស់លោកតា អ៊ុក នេន

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ អ៊ុក នេន

## <u>ការសង្ខេបប្រវត្តិរបស់ លោកតា អ៊ុក នេន</u>

លោកតា អ៊ុក នេន មានអាយុ73ឆ្នាំ នៅក្នុងឆ្នាំ2018 លោកតា អ៊ុក នេន មានភេទប្រុសលោកតា អ៊ុក នេន មានទីលំនៅបច្ចុប្បន្ននៅ វត្តដំដែកចាន់រង្សី សង្កាត់ជ្រោយចង្វារ នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនតាដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់តា ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗអោយពួកគាត់ បានស្គាល់នឹងបានដឹងពីប្រវត្តិរបស់ឪពុកម្តាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍តា ហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសតា ចឹងសំរាប់តាយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេតា?

ខៈ
ណែនេះហាសឥឡូវនឹងនិយាយអោយនិយាយរឿងជំនាន់ប៉ុន្មានៗៗនឹងមិនដឹងទេណាស់

កៈ
បាទ!!តាចង់និយាយថាតាយល់ព្រមដើម្បីអោយខ្ញុំសំភាសន៍តានឹងដើម្បីដាក់ទៅក្នុងវេបសាយរបស់សាលាហើយនឹងទុកអោយតា នឹងយកអោយតាវិញអីចឹងហាស?

ខៈ បាទ!!អានឹងអត់អីទេ

កៈ ចឹងបាទតាចឹងសូមតានិយាយអោយរៀងលឺបន្តិចណាស់តា?

ខៈ បាទ!!អានឹងអត់អីទេអូន

កះ ស្រួលខ្ញុំរ៉ិខតសំលេងចឹងហាសតា?

ខះ បាទ!!អត់មានអីទេអូន

កះ បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍តាខ្ញុំមានឈ្មោះថា ជាង ស៊ីអារ
ហើយថ្ងៃខែដែរខ្ញុំសំភាសន៍តាគឺនៅថ្ងៃទី14 ខែ6 ឆ្នាំ2018
គឺសំភាសន៍នៅនៅនឹងភូមិអីគេដែរតា?

ខះ នៅនេះណែវត្តដំដែក

កះ វត្តដំដែក?

ខះ ចាន់រង្សី

កះ នៅវត្តដំដែកចាន់រង្សី ចុះនៅសង្កាត់អីគេដែរតា?

ខះ ហាស?

កះ នៅសង្កាត់អីគេដែរតា?

ខះ ហ៊ឺ!!អ៊ុំមិនដឹងទេអត់ដឹងអីគេផងនឹង

កះ អត់ដឹងមួយនឹងនៅសង្កាត់ជ្រោយចង្វារហើអ៊ុំ?

ខះ នឹងទេដឹងនៅសង្កាត់ជ្រោយចង្វារនឹងអ៊ុំអត់ដឹងដែរនឹងហាស

កះ ចឹងហោសតាណា?

ខះ អ៊ុំនៅខេត្តកំពតនឹងហាសមកនៅឯលោកនឹង

កះ អូ៎!!បាទតាបាទចឹងមានន័យថាតាមកនៅនឹងតាំងពីតូចហើយណាតា?

ខះ អត់ទេៗៗអ៊ុំមកនៅឯលោកតែម្តងនឹង

កះ អូ៎!!បាទយល់បាទ?

ខះ អ៊ុំនៅកំពតនឹង នៅខេត្តកំពតនឹង

កះ ចឹងតានៅខេត្តកំពតហោស?

ខ៖ នៅខេត្តកំពតនឹង

ក៖ អ៎ូ!!បាទតាចឹង?

ខ៖ អត់ទេអត់នៅនេះទេបន្ទាប់មកអ៊ំទៅមកៗៗទេណាស់

ក៖ បាទ!!ចឹងអានឹងមួយនឹងនៅសង្កាត់ជ្រោយចង្វារ នៅរាជធានីភ្នំពេញណាតា?

ខ៖ អ៎ូៗៗ!!អូអានឹងអូនឯងដាក់ចឹងទៅ

ក៖ បាទ!!តាចឹងសំរាប់តាឈ្មោះពេញរបស់តានឹងមានឈ្មោះអីគេដែរតា?

ខ៖ ខ្ញុំហោសណៃ

ក៖ មានឈ្មោះទាំងត្រកូលចឹងហាសតា?

ខ៖ ឈ្មោះនាមត្រកូលហោស?

ក៖ បាទ!!តាបាទ?

ខ៖ ឈ្មោះអ៊ុក នេន

ក៖ ឈ្មោះអ៊ុក នេនចឹងតាមានឈ្មោះនេនណាតា?

ខ៖ បាទៗៗ!!នឹងហើយ ខ្ញុំឈ្មោះនេន នាមត្រកូលអ៊ុកចឹងហាស

ក៖ បាទ!!តាចុះតាមានឈ្មោះហៅក្រៅអត់តា?

ខ៖ អត់មានទេ

ក៖ ចឹងតាមានឈ្មោះតែមួយនឹងទេណាតា?

ខ៖ មានឈ្មោះតែមួយនឹងអត់ទេអត់មានច្រើនទេ

ក៖
ចុះកាលពីក្មេងធ្លាប់មានបងប្អូនរឺមួយក៏ធ្លាប់មានមិត្តភក្តិឪពុកម្តាយហៅឈ្មោះតាអីផ្សេងដែរអត់?

ខ៖ បងប្អូនថីមិនមានស្លាប់អស់ហើយ

កៈ ចឹងហោសតាហោស?

ខៈ អើរអស់ហើយនឹងគ្មានទេនៅតែកុងមួយទេ

កៈ អ្ហូ!!បាទតាចុះសំរាប់តាសព្វថ្ងៃតាអាយុប៉ុន្មានដែរតា?

ខៈ ណែអាយុ72-73ឆ្នាំហើយ

កៈ អាយុ73ឆ្នាំហោសតា?

ខៈ ចូលអាយុ73ឆ្នាំហើយនឹង

កៈ ចុះតាកើតនៅថ្ងៃខែឆ្នាំណាដែរតាមានចងចាំទេ?

ខៈ ហីភ្លេចអស់ហើយក្មួយអើយខ្ញុំវង្វេងវង្វាន់អស់ហើយនឹងចាស់

កៈ ចឹងហោសតា?

ខៈ វាភ្លេចនឹងហាស

កៈ បាទ!!តាបាទ?

ខៈ អាយុវាចូលត្រូវ73ឆ្នាំហើយណាស់

កៈ បាទ!!តាបាទ?

ខៈ ឥឡូវនឹងកុងភ្លេចអាឆ្នាំគេដែរនឹងហាសភ្លេចដែរនឹងហាស

កៈ ភ្លេចទាំងឆ្នាំទៀតហោសតា?

ខៈ ឥឡូវនឹងភ្លេចឆ្នាំហើយនឹង

កៈ បាទ!!

ខៈ អើរក្មួយឯងគិតមើលភ្លេចហើយនឹងហាស

កៈ ចុះថ្ងៃខែតាមានចងចាំអត់?

ខៈ ថ្ងៃខែអូនអើយគ្មានទេអត់ចាំទេភ្លេចអស់ហើយនឹង

កៈ ចឹងណាតាណា?

ខ៖ ភ្លេចអស់ហើយ

ក៖ អូ៎!!បាទតា?

ខ៖ ភ្លេចអស់ហើយក្មួយអើយ

ក៖ អូ៎!!បាទចុះតាសំរាប់ឆ្នាំច័ន្ទគតិតាឆ្នាំអីគេដែរលក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះអីហាសតា?

ខ៖ អូ៎!!អានឹងជូត ថោះប្អូនអើយ

ក៖ តាឆ្នាំអីគេដែរតា?

ខ៖ វាអាឡូវនឹងវាភ្លេចឆ្នាំទៀតនឹងហាសកុងហាស

ក៖ ចឹងហោសតា?

ខ៖ ទាល់តែសួរយាយរបស់ខ្ញុំបានដឹងខ្ញុំភ្លេចអស់ហើយនឹង

ក៖ ចុះយាយនៅណាដែរទៅតា?

ខ៖ អូ៎!!នៅស្រុកហោស

ក៖ ចុះសំរាប់តាគិតថាតាកើតនៅណាដែរតា?

ខ៖ កើតនៅឯស្រុកកុងនៅនោះនៅខេត្តកំពតនោះនឹង

ក៖ នៅខេត្តកំពតប៉ុន្តែនៅភូមិអី ឃុំអីដែរតា?

ខ៖ នៅភូមិណៃស្រុកកំពត់ត្រាច ឃុំណៃយស្វាយទង

ក៖ ចុះភូមិវិញ?

ខ៖ ឃុំស្វាយទងនឹងតែម្តងនឹង

ក៖ នៅភូមិស្វាយទង ឃុំស្វាយទង ស្រុកកំពង់ត្រាច

ខ៖ អើរៗៗស្រុកកំពង់ត្រាច

ក៖ នៅខេត្តកំពត់?

ខ៖ នៅខេត្តកំពត់អើរនឹងអានឹង

កៈ សំរាប់តាមានបងប្អូនចំនួនប៉ុន្មាននាក់ដែរតា?

ខៈ ពីរនាកើស្លាប់អស់ហើយអូនអើយនៅតែកុងម្នាក់ទេ

កៈ អូ៎!!មានតែពីរនាក់ទេហោសតា?

ខៈ អើរអស់ហើយនឹងនៅតែកុងម្នាក់ទេទាំងអស់វា4នាក់ណាស់

កៈ អូ៎!!ទាំងអស់4នាក់ហោស?

ខៈ អើរឥឡូវនឹងស្លាប់អស់3នាក់ហើយនៅតែកុងម្នាក់ទេ

កៈ អូ៎!!ប៉ុន្តែពួកគាត់ស្លាប់នៅពេលណាដែរតា?

ខៈ អូ៎!!យូរហើយនឹងស្លាប់តាំងពីជំនាន់មុនមកនឹងហាសស្លាប់តាំងពីមុនហោស

កៈ បាទ!!អូចឹង?

ខៈ តាំងពីសង្គមចាស់ហោសស្លាប់យូរហើយ

កៈ អូ៎!!មុនពលពតទៀតហោសតា?

ខៈ អើរយូរហើយស្លាប់យូរហើយស្លាប់តាំងពីណៃតាំងពីអ៊ីការហើយនឹងហាស

កៈ បាទ!!តា?

ខៈ យូរដែរហើយនឹងយូរឆ្នាំហើយនឹង

កៈ ចុះកើតអីបានជាពួកគាត់ស្លាប់ដែរតា?

ខៈ ហាស?

កៈ កើតអីបានជាពួកគាត់ស្លាប់ដែរ?

ខៈ គាត់ឈឺមើលមិនត្រូវណាស់អូនអើយ

កៈ ចឹងហោសតា?

ខៈ អើរមើលមិនត្រូវឈឺ

កៈ អូ៎!!ចុះសំរាប់បងប្អូនរបស់តានឹងមានស្រីប៉ុន្មាននាក់នឹងប្រុសប៉ុន្មាននាក់ដែរតា?

ខ៖ ណែមានស្រីតែមួយទេ នឹងប្រុស3នាក់ មានប្រុស3នាក់នឹងស្រីមានតែមួយទេនឹង

ក៖ ចុះតាជាកូនទីប៉ុន្មានដែរទៅនៅក្នុងក្រុមគ្រួសារហាស?

ខ៖ តាទីពីរនឹងតាណែបន្ទាប់ពីបងប្រុសណាស់

ក៖ បាទ!!តាបាទ?

ខ៖ ណែហើយមកដល់ក្រោយនឹងមកប្អូនស្រីបន្ទាប់ពីខ្ញុំចឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ ហើយដល់មួយពៅនឹងបន្ទាប់ពីមួយស្រីនឹង

ក៖ និយាយរួមនឹងបន្ទាប់ៗគ្នាណាតា?

ខ៖ អើរបន្ទាប់ៗគ្នានឹង

ក៖ ចុះតាគិតថាបងប្អូនរបស់តានឹងមានឈ្មោះអីគេតាមានចងចាំឈ្មោះគាត់ដែរទេ?

ខ៖ មើលទី1ណែ

ក៖ បងគេចឹងហាស?

ខ៖ ទី1ឈ្មោះអ៊ុក ត្រើង

ក៖ ឈ្មោះកុក ត្រើង?

ខ៖ ឈ្មោះអ៊ុក ត្រើង អើរឈ្មោះអ៊ុក ត្រើងនឹង

ក៖ នឹងបងទី1នឹងហោសតា?

ខ៖ អើរបងទី1នឹងហើយ ហើយដល់មកខ្ញុំនឹងហាស

ក៖ បន្ទាប់មកបានតា?

ខ៖ ហើយមកដល់មួយស្រីណោះស្រីប្អូនរបស់ខ្ញុំនឹងហាសឈ្មោះញៀម

ក៖ មានឈ្មោះញៀម?

ខ៖ បាទ!!ឈ្មោះញៀម

កៈ ចុះប្អូនពៅនឹងមានឈ្មោះអីគេដែរតា?

ខៈ ប្អូនពៅនឹងស្លាប់យូរហើយនឹងស្លាប់តាំងពីយើងបែកហើយនឹងហាស

កៈ ប៉ុន្តែ?

ខៈ ឈ្មោះណុប

កៈ ឈ្មោះណុប ណាតា?

ខៈ នឹងហើយឈ្មោះណុប

កៈ ចុះតាមានកូនប៉ុន្មាននាក់ដែរតា?

ខៈ ខ្ញុំមានកូន6នាក់

កៈ មានកូន6នាក់ប៉ុន្តែចុះពួកគាត់ឥឡូវនឹង?

ខៈ មាន6នាក់នឹងនៅទាំងអស់កូនរបស់ខ្ញុំ

កៈ ចឹងនៅទាំងអស់ណាតាណា?

ខៈ បាទ!!នៅទាំងអស់នឹង

កៈ អូ្ហ!!ប៉ុន្តែមានចៅហើយហីតា?

ខៈ ចៅមានចៅច្រើននឹងមានជិត20នាក់ហើយចៅនឹង

កៈ អូ្ហ!!ប៉ុន្តែឥឡូវនឹងពួកគាត់នៅនឹងទាំងអស់គ្នា?

ខៈ នៅណុងនៅស្រុកនឹង

កៈ គាត់នៅស្រុកណុងហោសតា?

ខៈ នៅស្រុកនឹងចៅទួតចៅអីនឹងមានហើយ

កៈ អូ្ហ!!ប៉ុន្តែតាមកនៅនឹងធ្វើអីគេដែរតា?

ខៈ នៅលោកលោកកូនមករៀននៅនេះហាស

កៈ អូ្ហ!!លោកកូនហោស?

ខ៖ អើរលោកកូន

ក៖ ប៉ុន្តែតាមកនៅនឹង?

ខ៖ ទៅមកៗៗអូនអើយ

ក៖ អូ!!ចឹងទេហោសតា?

ខ៖ ហើយថ្ងៃនេះទៅវិញហើយនឹងហាស

ក៖ អូ!!ថ្ងៃនេះទៅវិញហើយហោសតា?

ខ៖ អត់ទាន់ទៅទេតិចទៀតបានទៅទៅមកៗៗនឹង

ក៖ អូ!!ចឹង?

ខ៖ ថ្ងៃណាទៅៗៗថ្ងៃណាមកៗៗវិញចឹងទៅណាស់

ក៖ បាទ!!តាបាទចុះតាគិតថាចឹងបងប្អូនរបស់តាស្លាប់អស់ហើយណតា?

ខ៖ ស្លាប់អស់ហើយនៅតែខ្ញុំទេ

ក៖ ចុះតាមានចងចាំថាកាលពីតានៅក្មេងជាមួយបងប្អូនរបស់តាហាស
តាធ្លាប់លេងអីជាមួយគ្នាជាមួយគាត់អត់ជាអនុស្សាវរីយ៍អីចឹងហាស?

ខ៖ អូ!!ចឹងយើងកាលនឹងលេងយើងនៅដើរក្មេងៗលេងនៅស្រុក
លេងបាញ់ឃ្លីបាញ់អីនឹងហាស

ក៖ លេងបាញ់ឃ្លីហោសតា?

ខ៖ បាញ់ឃ្លីអីវិននឹងហោស

ក៖ អូ!!ប៉ុន្តែលេងបិទពួនលេងបាយឡឹកបាយឡអីដែរ?

ខ៖ អើរលេងបិទពួន លេងបាយឡឹកបាយឡអីដែរនឹងលេងប៉ាវពួនអីចឹងទៅណាស់

ក៖ លេងប៉ាវពួនអីចឹង?

ខ៖ អើរអានឹងចឹងហើយលេងប៉ាវពួនអីចឹង
លេងកន្សែងលេងបោះកន្សែងចោលកន្សែងអីចឹងទៅណាស់

កៈ អ៊ូ!!ហ្វបាទតាបាទ?

ខៈ អើរនឹងហើយចឹង

កៈ ប៉ុន្តែធ្លាប់ទៅស្រែជាមួយពួកគាត់ដែរទេតា?

ខៈ ធ្វើអូនធ្វើ

កៈ ប៉ុន្តែពេលណុងតាទៅស្រែធ្វើអីគេខ្លះជាមួយពួកគាត់ដែរទៅ?

ខៈ ធ្វើរាល់ឆ្នាំនឹងនៅតែធ្វើចឹងហាសតែឥឡូវនឹងលែងធ្វើហើយជួលគេធ្វើនឹង

កៈ បាទ!!តាបាទ?

ខៈ ឥឡូវនឹងចាស់ហើយធ្វើអីកើតអូនធ្វើមិនកើតអោនមិនកើតទេ

កៈ បាទ!!តាបាទ?

ខៈ យ៉ាប់ហើយណាស់មិនងាយទេ

កៈ ចុះសំរាប់ឪពុករបស់តាមានឈ្មោះអីគេដែរតា?

ខៈ អ៊ូ!!ឈ្មោះតាផាន់

កៈ មានឈ្មោះតាផាន់ ចុះយាយវិញ?

ខៈ យាយឈ្មោះយាយញឹម ឈ្មោះយាយញឹមហាស

កៈ បាទ!!តាចុះតាមានដឹងថាឪពុករបស់តានឹងអាយុប៉ុន្មានដែរទេតាទាល់ឥឡូវនឹងហាស?

ខៈ ហេកាលស្លាប់នឹងយូរដែរហើយនឹងហាសអត់ចាំទេកូន

កៈ អាយុច្រើនហើយណាតា?

ខៈ អាយុច្រើនៗហើយអត់ដឹងទេ

កៈ ចុះយាយយាយតាមានដឹងថាអាយុប៉ុន្មានទេ?

ខៈ យាយអត់ចាំអាយុយាយដែរនឹងស្លាប់ហើយនឹង

កៈ ពួកគាត់មានអាយុច្រើនៗហើយពីព្រោះតាឥឡូវនឹងអាយុ72ឆ្នាំហើយណាតា?

ខ៖ អើរ ៗ ៗ អាយុ72ឆ្នាំហើយអត់ចាំទេអូនអើយ

ក៖ ចុះឪពុករបស់តានឹងគាត់កើតនៅណាតាមានដឹងអត់?

ខ៖ គាត់កើតនៅស្រុកនឹងតែម្ដងនឹង

ក៖ នៅកំពតនឹងតែម្ដង?

ខ៖ អើរនៅកំពតនឹងតែម្ដងនឹង

ក៖ ចុះយាយវិញ?

ខ៖ យាយក៏នៅនឹងដែរ

ក៖ ចឹងហោសតា?

ខ៖ អើរនៅឃុំស្រុកជុំគ្នាទាំងអស់នឹង

ក៖ បាទ!!តាបាទ?

ខ៖ នៅស្រុកជាមួយគ្នានឹងហាសអូន

ក៖ ចុះអើរឪពុករបស់តាកាលពីគាត់នៅរស់គាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតនឹងចិញ្ចឹមក្រុមគ្រួសារដែរតា?

ខ៖ ធ្វើស្រែធ្វើភ្លឺរកស៊ីចិញ្ចឹមកូនអីចឹងទៅណាស់

ក៖ អូ៎!!តែគាត់ធ្វើតែស្រែទេហោសតា?

ខ៖ នឹងចឹងគាត់ធ្វើតែស្រែទេគាត់អត់មានធ្វើអីទេនឹង
ធ្វើតែស្រែធ្វើកម្មករនឹងហាសអត់មានធ្វើអីទេធ្វើស្រែ

ក៖ ចុះឪពុករបស់តាគាត់ស្លូតរឺមួយក៏កាចដែរតា?

ខ៖ អត់ទេស្លូតដែរនឹងហាសអត់កាចទេ

ក៖ គាត់ស្លូតទេណតា?

ខ៖ មិនដែរឈ្លោះគ្នាជាមួយនរណាទេ

កៈ អូ៎!!ចុះម្ដាយរបស់តាវិញគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតនឹងចិញ្ចឹមក្រុមគ្រួសារដែរតា?

ខៈ ធ្វើណែនឹងហៅប្រាប់ក្មួយត្រង់ធ្វើកន្ទេលអញ្ចូតៗនឹងហាស

កៈ បាទ!!កន្ទេលអញ្ចូតនឹងយើងនឹងហោស?

ខៈ អើរកន្ទេលអញ្ចូតនឹង

កៈ ធ្វើយកទៅលក់ណាតា?

ខៈ អើរធ្វើយកទៅលក់នឹងហាស

កៈ អូ៎!!បាទចឹងយាយធ្វើតែមួយនឹងទេណាតា?

ខៈ អើរធ្វើតែអានឹងទេគ្មានធ្វើអីទេក្មួយហាសទាល់រាល់ថ្ងៃនឹងក៏នៅតែធ្វើដែរណាស់ រាល់ថ្ងៃនឹងចៅរបស់តានៅធ្វើដែរ

កៈ អូ៎!!គាត់នៅតវេនអោយកូនចៅទៀតហោសតា?

ខៈ
អើរៗៗចៅទៀតហាសតឥឡូវនឹងគាត់ស្លាប់ហើយនៅតមកដល់កូនចៅអីធ្វើទៀតនឹងហាស តគ្នានឹងហាស

កៈ អូ៎!!ធ្វើអានឹងលក់បានថ្លៃមែនតា?

ខៈ បាននៅផ្ទះបានមួយ3ម៉ឺនជាងអីនឹងហាស

កៈ អូ៎!!ចឹងធ្វើប៉ុន្មានថ្ងៃទៅហើយមួយដែរតា?

ខៈ ហ៎ា!!3-4ថ្ងៃដែរនឹងខំ

កៈ អូ៎!!ខំ3-4ថ្ងៃបានបានមួយ?

ខៈ ខំអានឹងពិបាកធ្វើបើអ្នកមានគេមិនធ្វើទេ

កៈ ប៉ុន្តែអានឹងធ្វើលក្ខណះថា?

ខៈ អានឹងធ្វើល្មមតែហើយត្រូវបកអោយទន់បានយើងជល់ហោស

កៈ បាទ!!ហើយបានយើងចាក់វាណាតា?

ខ៖ ត្បាញ់អើរអានឹងចាក់វាឆ្នូតវាឬស្សីនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ ឬស្សីជល់វាហើយហូតចឹងមកណាស់

ក៖ បាទ!!តាបាទ?

ខ៖ មិនងាយធ្វើទេអ្នកខ្លះគេមិនធ្វើទេ

ក៖ ចុះតាគិតថាសំរាប់ធ្វើអានឹងយើងធ្វើតែម្នាក់ឯងរឺក៏យើងធ្វើគ្នាច្រើនដែរសំរាប់3-4ថ្ងៃចឹងហាស?

ខ៖
អានឹងដូចថាអូនឯងអុំលើកមួយចឹងទៅនឹងមួយងារចឹងហើយទៅដូចថាបើកូនមកក្រោយលើកត មួយងារទៀតចឹងទៅ

ក៖ បាទ!!តាបាទ?

ខ៖ អានឹងដូចថាហើយអាមួយសាច់អីចឹងកន្លះម៉ែត្រអីហើយអានឹងហាស
គេហៅមួយជល់មួយសាច់អី នឹងហាស

ក៖ មួយឆ្នូតមួយសាច់?

ខ៖ អើរមួយឆ្នូតមួយសាច់ហើយដល់ពេលតទៀតហើយអានឹងបុកមួយសារទៀតជល់ទៀត

ក៖ អូ៎!!ចឹងទេហោសតា?

ខ៖ នឹងហើយជល់ទៀតនឹង

ក៖ បាទ!!តាបាទ?

ខ៖ ធ្វើ3ថ្ងៃខំបានហើយអានឹងរួចមួយហាស

ក៖ បាទ!!តាបាទ?

ខ៖ ពិបាកធ្វើណាស់ពិបាកមាំណាស់កុំថាស្រួលហាស

ក៖ បាទ!!ចឹងមានន័យថា?

ខ៖ អានេះបុកផងអីផងប្អូនឯងជល់អានេះមិនរាប់សរសៃទេណាស់

ក៖ បាទ!!តាបាទ?

ខ៖ ហើយកាសដាច់អស់ហើយក្រចកនឹងហាស

ក៖ ប៉ុន្តែតាគិតថាកូនចៅរបស់តានៅតែធ្វើអានឹងរាល់ថ្ងៃ?

ខ៖ នៅធ្វើនឹងនៅតែធ្វើរាល់ថ្ងៃនឹងហាស

ក៖ ដោយសារតែយើងអត់ដឹងថាយើងរកស៊ីអីទេណតា?

ខ៖ អត់ដឹងថារកស៊ីអីនឹងអាខ្លះឥឡូវនឹងគេមកពោងចក្រអីចឹងទៅណាស់

ក៖ បាទ!!តាបាទ?

ខ៖ តែឥឡូវនឹងគេមិនធ្វើទេបើថាចាស់ៗៗនៅតែធ្វើចឹងហាស

ក៖ បាទ!!ចុះម្ដាយរបស់តាគាត់ស្លូតរឺមួយក៏កាចដែរតា?

ខ៖ អត់ទេអូនអត់កាចទេ

ក៖ ចឹងស្លូតទេណតា?

ខ៖ ឪពុកនឹងម្ដាយរបស់អ៊ុំអត់ចេះទេតានឹងអត់ចេះទេអត់មានចេះធ្វើអីទេ

ក៖ ចុះតាមានចងចាំអនុស្សាវរីយ៍អីថាកាលពីតានៅជាមួយឪពុកម្ដាយរបស់តាដែរទេ?

ខ៖
អត់មានទេអូនអើយថាមួយជីវិតនេះកុងហើយអត់មានសង្សារអីណាៗៗអីនឹងអត់មានទេ

ក៖
អត់ទេដូចថាតាធ្លាប់ទៅណាជាមួយឪពុកម្ដាយលក្ខណះថាធ្វើការអីជាមួយគាត់ចឹងហាស?

ខ៖ អូ៎!!អានឹងអត់មានទេអត់ទេ

ក៖ អត់ទេណតាណ?

ខ៖ អត់មានទេ

កៈ តែធ្លាប់ទៅធ្វើស្រែអីជាមួយឪពុករបស់តាទេ?

ខៈ ទៅធ្វើស្រែនឹងទៅធ្វើតែស្រែទេ

កៈ អូ៎!!បាទតាបាទ?

ខៈ គ្មានគិតអីណាសង្ស័រអីណាៗៗដូចឥឡូវនឹងទេពីមុននឹងគ្មានទេ

កៈ ចុះតាគិតថាតាមានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីនៅក្មេងទៅតាដែរទេ?

ខៈ នៅក្មេងនឹងគាត់ធ្វើអីចាស់ៗៗនឹង

កៈ កាលពីគាត់អត់ទាន់មានគ្រួសារ?

ខៈ អូ្វ!!គាត់មានគ្រួសារម៉េចដឹងអ៊ីម៉េចដឹង

កៈ គាត់អត់ដែរប្រាប់ទេណា?

ខៈ ទេអត់ដឹងទេ

កៈ អូ៎!!ចុះតា?

ខៈ យើងឥឡូវនឹងណែយើងនៅកំលោះម៉េចដឹងយើងកូនគាត់ចឹងយើងម៉េចដឹង

កៈ ប៉ុន្តែគីឡូពេលខ្លះគាត់ប្រាប់យើងចឹងហាស?

ខៈ
អត់គាត់មិនដែរប្រាប់ទេគាត់មិនដែរនិយាយអីទេគាត់និយាយតែតាយាយគាត់នឹងហាស
គាត់និយាយតែឪពុកម្តាយរបស់គាត់នឹងហាសពិបាកណាស់

កៈ អូ៎!!ចឹង?

ខៈ ពិបាកតែធ្វើស្រែធ្វើភ្លឺនឹងហាសជាកម្មករនឹងហើយ

កៈ អូ៎!!បាទតាចុះយាយវិញគាត់មានដែរប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅតាដែរទេ?

ខៈ ពិបាកអូនធ្វើអូនអើយគាត់ពិបាកណាស់

កៈ អូ៎!!បាទតាបាទ?

ខ៖ ពិបាកណាស់

ក៖ ចុះគាត់?

ខ៖ ធ្វើតែកន្ទេលទេគា្មនទៅធ្វើអីទៀតទេ

ក៖ ចុះឪពុករបស់តាដូចជាយាយតាខាងឪពុកនឹងតាមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ថាម៉េច?

ក៖ យាយតាខាងឪពុករបស់តាហាស?

ខ៖ យាយស្លាប់ហើយហេយាយស្លាប់តាអត់ទាន់ទេ

ក៖ ប៉ុន្តែពួកគាត់មានឈ្មោះអីគេដែរតាមានចងចាំអត់?

ខ៖ តាអត់ទាន់ទេអូនអើយ

ក៖ តាអត់ទាន់ទេណតា?

ខ៖ លឺតែគាត់និយាយតែតាអត់ទាន់ទេនឹង

ក៖ តែគាត់មានដែរប្រាប់ឈ្មោះថាយាយតាខាងឪពុកនឹងគាត់មានឈ្មោះអីគេដែរទេ?

ខ៖ វាយូរដែរហើយវាភ្លេចអស់ហើយតានឹងយើងនៅក្មេងៗៗនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ វាមិនដឹងនឹងហាសយើងមិនដែរបានសួររៀបរាប់អីនឹងអត់កាលណុង

ក៖ បាទៗ!!តាចុះ?

ខ៖ ភ្លេចអស់ហើយនឹង

ក៖ ចុះអើរយាយតាខាងម្តាយវិញតាមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ អត់ទេ

ក៖ អត់ចាំដែរហោសតា?

ខ៖ អត់ចាំទេ

កៈ និយាយរួមនឹងតាទាន់គាត់ដែរទេ?

ខៈ អត់ទេអូនអើយអត់ទេ

កៈ តាកើតអត់ទាន់ទេណាតាណា?

ខៈ តាកើតអត់ទាន់ទេ

កៈ អូ៎!!ចុះសំរាប់?

ខៈ គាត់ស្លាប់យូរហើយចឹងតាអត់ទាន់ទេ

កៈ ចុះសំរាប់អើរតាគិតថាតារស់នៅខេត្តកំពតនឹងយូរហើយណាតាណា?

ខៈ យូរហើយអូនអើយយូរហើយនឹង

កៈ អូ៎!!

ខៈ អត់មានទៅនៅណាទេស្រុកកំណើតនៅនឹង

កៈ ចឹងអត់មានផ្លាស់ទីលំនៅទៅនៅណាអីទេ?

ខៈ អត់មានទេទាល់តែតឡូវនឹងគ្មានដែរទៅណានៅតែកន្លែងដដែលនឹងហាស

កៈ អូ៎!!បាទតាបាទ?

ខៈ នៅតែនឹង

កៈ ចុះតាគិតថាតាមានកូនចៅណាដែរទៅរស់នៅក្រៅប្រទេសទេតា?

ខៈ អត់ទេអត់មានទេ

កៈ មានតែនៅស្រុកខ្មែរទេណាតា?

ខៈ មានតែនៅស្រុកខ្មែរនឹង

កៈ អូ៎!!ចុះភរិយារបស់តានឹងមានឈ្មោះអីគេដែរតា?

ខៈ អើរយាយយាយរបស់ខ្ញុំនឹងហោស?

កៈ បាទ!!តាបាទ?

ខ៖ យាយរបស់ខ្ញុំនឹងប្រាប់ឈ្មោះមិញនឹងអត់លឺទេហី?

ក៖ មានឈ្មោះអីគេដែរតា?

ខ៖ មានឈ្មោះទូ យ៉ាន់

ក៖ មានឈ្មោះទូ យ៉ាន់?

ខ៖ អើរនឹងហើយប្រាប់ឈ្មោះអូនឯងមិននឹងអត់ឃើញទេហី

ក៖ អ៎ូ!!ខ្ញុំភ្លេចចុះតាគិតថាអើរតារៀបអាពាហ៍ពិពាហ៍ជាមួយយាយនឹង
នៅថ្ងៃខែឆ្នាំណាដែរតាមានចងចាំទេ?

ខ៖ ហ៎េ!!កាលខែឆ្នាំនឹងវាភ្លេចអស់ហើយអូនវាភ្លេចអស់ហើយនឹង

ក៖ ប៉ុន្តែ?

ខ៖ នឹកមិនឃើញទេ

ក៖ ប៉ុន្តែដូចជាតា?

ខ៖ ដល់ពេលចាស់ចឹងភ្លេចៗៗដូចជាមិនដឹងទេ

ក៖ ប៉ុន្តែកូនរបស់តានឹងអាយុប៉ុន្មានដែរកូនបងហាស?

ខ៖ កូនបងអាយុហាជាងហើយនឹង

ក៖ ចឹងមានន័យថាតាការក៏អស់50ឆ្នាំជាងដែរហើយនឹង?

ខ៖ នឹងអស់50ឆ្នាំជាងហើយនឹង

ក៖ អ៎ូ!!បាទតាបាទ?

ខ៖ អស់50ឆ្នាំជាងហើយដូចជា55ឆ្នាំហើយនឹងកូនបងហាស

ក៖ អ៎ូ!!បាទតាបាទចុះ?

ខ៖ តាការតាំងពីសម្តេចឪនៅឯករាជ្យនឹងមក

ក៖ អ៎ូ!!បាទតាចុះ?

ខ៖ វាយូរដែរហើយនឹងហាសប៉ុន្មានជំនាន់ហើយគិតមើល

ក៖ ចុះតាគិតថានៅពេលដែរតាចូលស្ដីដណ្ដឹងយាយនឹងដូចជាមានជាជំនូនជូនយាយអត់កាលពីជំនាន់ណុងចឹងហាស?

ខ៖ កាលពីជំនាន់ណុងយើងការអត់មានស្អីទេឥឡូវទៅដណ្ដឹងហូបផ្លែឈើអីនឹងមិនខ្វះទេ

ក៖ អូ!!ប៉ុន្ដែតា?

ខ៖ កាលយើងការមុននឹងមានផ្លែឈើ មាននុំកម នុំអន្សមអីនឹងមិនខ្វះទេណាស់

ក៖ បាទ!!តាបាទ?

ខ៖ ស្រួលរៀបហាសណាស់

ក៖ ប៉ុន្ដែកាលតាចូលស្ដីដណ្ដឹងយាយនឹងនៅជំនាន់ណាដែរតា?

ខ៖ កាលនៅជំនាន់យើងជំនាន់សង្គមសម្ដេចសីហានុនឹងហាស

ក៖ អូ!!កាលនៅជំនាន់ហាជាងរឺក៏ជំនាន់ហុកជាងដែរតា?

ខ៖ នៅជំនាន់ហាជាងទៅហុកជាងនឹងហាស

ក៖ បាទៗ!!តាបាទ?

ខ៖ កុងការបានប៉ុន្មានបានគេធ្វើរដ្ឋប្រហារនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ វាយូរដែរហើយនឹង

ក៖ ចុះតាគិតថាតាស្រលាញ់យាយនៅពេលណាដែរទៅ?

ខ៖ ស្រលាញ់គ្នាកាលពីនៅក្មេងដល់ពេលដែរចាស់ៗៗទៅនឹងមិនសូវស្រលាញ់គ្នាទេចាស់ៗៗទៅបែកគ្នាអស់ហើយនឹង

ក៖ ប៉ុន្ដែចុះកាលនៅក្មេងនឹងតា?

ខ៖ ឥឡូវនឹងនៅក្មេងបើមិនស្រលាញ់ម៉េចបានទៅណ

ក៖ 
បាទ‼ប៉ុន្តែតាគិតថាតាលួចស្រលាញ់យាយប៉ុន្មានឆ្នាំដែរហើយបានតាចូលស្ដីដណ្ដឹងយាយ?

ខ៖ អ៊ូ‼ពីរឆ្នាំទៅបីឆ្នាំហើយនឹងល្មមនឹងបានគ្នានឹងហោស

ក៖ មានឧបសគ្គច្រើនណាតា?

ខ៖ មានច្រើនហើយមិនមែនថាអត់មានទេស្គាល់យូរដែរនឹង

ក៖ អ៊ូ‼ចឹងហោសតា?

ខ៖ ល្មមបានការអីដែរនឹងយូរការដែរយូរឆ្នាំដែរនឹងហាស

ក៖ បាទ‼តាបាទចុះតាគិតថាតាធ្លាប់បានរៀនភាសាខ្មែរពីមុនទេតា?

ខ៖ អត់ទេអូនអត់មានទេ

ក៖ កាលពីជំនាន់ណុងអត់បានរៀនអីទេណតា?

ខ៖ អត់បានរៀនអីទេអូនអត់ដែរចេះតែរឹកដើរលេង

ក៖ ចេះតែដើរលេង?

ខ៖ ដើរពេកបួសភ្លេចរៀនអស់ហើយនឹងហាស

ក៖ អ៊ូ‼ចឹងហោសតា?

ខ៖ គិតថាដើរលេងពេលបួសទៅភ្លេចអស់ហើយនឹងកុងហាស

ក៖ អត់បានបួសដែរ?

ខ៖ អត់ទេអត់នឹងហាស

ក៖ អ៊ូ‼ចឹង?

ខ៖ 
កាលណុងក្មួយឯងមើលស្ដាយចង់ស្លាប់ហើយនឹងហាសឥឡូវនឹងដល់ពេលចាស់ហើយនឹងជ្រុល ហើយនឹងចប់

ក៖ បាទ!!តាបាទប៉ុន្តែយើងអាចសំសិល្ប៍បានធម្មតា?

ខ៖ បាតដៃរបន្តិចបន្តួចនឹងហាសបានដៃរនឹង

ក៖ បាទ!!អូ?

ខ៖ ដោះស្រាយបន្តិចបន្តួចរួចខ្លះដៃរចឹងទៅណាស់អត់ចាំដៃរនឹងហាស

ក៖ បាទ!!តាបាទនឹង?

ខ៖ ពេលណាចាំទៅទៅៗៗពេលណាអត់ចាំភ្លេចឈប់ដៃរនឹងហាស

ក៖ អ្ហូ!!ចឹងហោសតា?

ខ៖ អានឹងវាចឹងហាស

ក៖ ប៉ុន្តែតាមានចេះភាសាអីក្រៅពីភាសាខ្មែរអត់តា?

ខ៖ ហាសថាម៉េច?

ក៖ តាមានចេះភាសាអីក្រៅពីភាសាខ្មែរដៃរទេ?

ខ៖ អត់ទេអត់ទេអានឹងហាសអត់ចេះទេ

ក៖ កាលពីជំនាន់តានឹងគេមានរៀនបារាំងអីដៃរណាតា?

ខ៖ គេរៀនដៃរនឹង

ក៖ តាអត់បានរៀនទេ?

ខ៖ អត់ទេអូនអត់ទេ

ក៖ អ្ហូ!!កើតអីបានជាតាអត់បានរៀនចឹងហោសតា?

ខ៖ បើក្មួនៗៗរិននឹងក្មួនអត់បានរៀននឹង

ក៖ អ្ហូ!!បាទៗៗតាបាទ?

ខ៖
វាស្តាយវាស្រលាញ់ស្រីចឹងវាខកអស់ហើយនឹងវាគ្មានបានរៀនអីណាពិបាកដែរនឹងគួរគិតទៅ

ក៖ បាទ!!តាបាទ?

ខ៖ បើវាគិតទៅវាស្តាយក្រោយនឹង

ក៖ បាទ!!តានឹងហើយតាបាទ?

ខ៖ វាចេះស្តាយមុនទេណាស់ក្មួយ

ក៖ បាទ!!ចឹងតា?

ខ៖ និយាយលេងទេណាស់

ក៖
ចុះតាគិតថាអើរតាធ្លាប់មានមិត្តភក្តិពីមុនអត់តាកាលនៅក្មេងៗហាសមិត្តភក្តិដែរស្និទ្ធិស្នាល អីចឹងហាសតាមានទេ?

ខ៖
អ៊ូ!!មិត្តភក្តិនឹងពិបាកនិយាយណាស់អូនមិត្តភក្តិបើនិយាយទៅវាច្រើនគ្នាណាស់អាយើងស្រលាញ់ទៅ បានអាយើងអត់ស្រលាញ់វិញចឹងទៅណាស់

ក៖ អ៊ូ!!បាទតាបាទ?

ខ៖ អាស្រលាញ់គ្នាមាំនឹងអត់បានគ្នាទេណាស់

ក៖ បាទ!!តាបាទ?

ខ៖ អត់ស្រលាញ់ទៅស្រលាញ់អត់ស្រលាញ់បានតិចមកវិញចឹងហាសណាស់

ក៖ ប៉ុន្តែតាធ្លាប់មានមិត្តភក្តិកាលពីនៅក្មេងដែរតើហីតា?

ខ៖ អ៊ូ!!មានដែរនឹងហាស

ក៖ ប៉ុន្តែតាធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេ?

ខ៖
ចឹមិនមានាមានដែរនឹងហាសដូចថាអុំនិយាយចឹងទៅអត់បានអាស្រលាញ់ទៅបានអាអត់ស្រលាញ់ អត់បានទេពីមុនមកបានអាអត់ស្រលាញ់វិញនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ នឹងវាចឹងហើយនឹង

ក៖ ចង់និយាយថាតាធ្លាប់ទៅដើរលេងជាមួយមិត្តភក្តិរបស់តាអីដែរទេ?

ខ៖ កាលមុននឹង

ក៖ មានអនុស្សាវរីយ៍អីជាមួយមិត្តភក្តិដែរចឹងហាស?

ខ៖ កាលពីមុនធ្លាប់ដើរដែរនឹងហាសកាលពីមុនដើរលេងដែរនឹងហាស

ក៖ ដូចជាតាគិតថា?

ខ៖ ដើរបានតែម្តងនៅពេលបុណ្យកថិនទេណាស់

ក៖ បាទ!!តាបាទ?

ខ៖ អើរបើថាក្រៅពីនឹងគ្មានទេ

ក៖ អូ៎!!ចឹងហោសតាហោស?

ខ៖ គ្មានទេនឹងដូចថាកថិនម្តងៗៗមិត្តភក្តិហៅទៅដើរលេងចឹងទៅហើយក៏ទៅៗៗនឹង

ក៖ បាទ!!ប៉ុន្តែតាធ្លាប់ធ្វើស្រែដែរណាតា?

ខ៖ ទៅធ្វើអូនធ្វើតើ!!

ក៖ នៅស្រែតាធ្វើអីគេខ្លះដែរទៅតា?

ខ៖ គ្មានទេធ្វើតែស្រែនឹងហាស

ក៖ មានដកស្ទូង ច្រូតកាត់អីនឹងហាស?

ខ៖ អើរមានដកស្ទូង ច្រូតកាត់អីនឹងហាស

ក៖ អូ!!បាទតាបាទ ចុះតាគិតថាជីវិតរបស់តាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងតាធ្លាប់ធ្វើការងារអីគេខ្លះដែរទៅតា?

ខ៖ អូ!!រឿងធ្វើការងារនឹងខ្ញុំវាឆ្អែតអស់ហើយក្មួយអើយ

ក៖ ចុះទៅស្រែ?

ខ៖ ខ្ញុំគេធ្វើការងារអីចិនចឹងហាសណាស់

ក៖ បាទ!!តាបាទ?

ខ៖ យើងរែកដីយើងរែកអំបិលធ្វើកម្មករអោយស្រែអំបិលចឹងទៅណាស់

ក៖ បាទ!!តាបាទ?

ខ៖ ធ្វើឆ្អែតអស់ហើយណាស់កុងអីវិននឹង

ក៖ អូ!!បាទតាចុះ?

ខ៖ ពិបាកណាស់ក្មួយពិបាកមាំតែម្តងនឹងហាស

ក៖ អូ!!បាទតាចុះតាដូចជាធ្លាប់ចិញ្ចឹមសត្វអីទេតា ដូចថា?

ខ៖ ចិញ្ចឹមដែរនឹងដូចថាយើងចិញ្ចឹមមាន់ ចិញ្ចឹមគោអីចឹងនឹងហាស

ក៖ អូ!!ចឹងហោស?

ខ៖ ចិញ្ចឹមគោ មានចិញ្ចឹមគោពីរបីអីចឹងមានមួយនឹមពីរនឹមចឹងទៅណាស់

ក៖ បាទ!!តាបាទ?

ខ៖ ធ្វើកាលណុងយើងធ្វើភ្ជួរតែស្រែនឹងគោនឹង

ក៖ បាទ!!តាបាទ?

ខ៖ មិនមែនដូចយើងសម័យឥឡូវនឹងភ្ជួរអាត្រាក់ គោយន្តណា

ក៖ បាទ!!តាបាទនឹង?

ខ៖ ដល់ពេលឥឡូវនឹងមានគោគ្មានបានយកទៅភ្ជួរទេគ្រាន់តែយកទៅលក់នឹង

ក៖ បាទៗៗ!!តាបាទ?

ខ៖ ឥឡូវនឹងកាន់អង្ករនឹងលែងកើតហើយនឹងចាស់ហើយ

ក៖
ចុះតាគិតថាជីវិតរបស់តាមានការផ្លាស់ប្ដូរអីគេខ្លះដែរទៅតាតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ អត់ទេអូនអត់ទេ

ក៖ អត់មានការផ្លាស់ប្ដូរអីទេណាតា?

ខ៖ អត់ៗៗអត់មានទេ

ក៖ និយាយទៅធម្មតា?

ខ៖
អត់ទេនឹងគ្មានអីក្នុងខ្លួនឥឡូវនឹងអាយុប៉ុន្មានអត់មានស្អីទេអានឹងពេលដែរចាស់ទៅនឹងកាលពី ពីរបីថ្ងៃមុននឹងពេលដែរស៊ីអីទៅវារៀងឆ្អល់ពោះហាស

ក៖ បាទ!!តាបាទ?

ខ៖ ហើយដល់ពេលដែរយើងចាស់ទៅនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ ហើយយើងចុកជើងអត់បាត់ទេក្មួយ

ក៖ បាទ!!តាបាទ?

ខ៖ ចុកជើងរាល់ឆ្នាំនឹងមិនដែរចុកទេណាស់

ក៖ បាទ!!តាបាទនឹង?

ខ៖
ដល់ពេលឆ្នាំនឹងចុកជើងហាសឥឡូវនឹងអន់ចុកកាលពីមុននឹងពាក់ស្បែកជើងអត់បានទេចុកអស់

ក៖ ហេតុអីទៅតា?

ខ៖ អើរ

ក៖ កើតអីគេដែរតា?

ខ៖ អត់មានកើតអីគេទេជើងតែវាយូរទៅនឹងវាចុកជើងនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ ចុកកាលពីមុននឹងពាក់ស្បែកជើងអត់បានទេណាស់កាលពីមុននឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ ហើយចេះតែរឹតនឹងរឹតៗៗទៅព្រលឹមឡើងចេះតែទៅហាត់ប្រាណចឹងទៅ

ក៖ យើងឧស្សាហ៍ហាត់ប្រាណចឹងហាសណាតា?

ខ៖ អើរហាត់ប្រាណទៅហាត់បន្តិចៗៗហាត់ទៅហាត់មកចឹងទៅណាស់អូន

ក៖ យូរទៅលែងអីហើយណាតា?

ខ៖ អើរដល់ឥឡូវនឹងបានពាក់ស្បែងជើងដឹងថាជើងនឹងយ៉ាងម៉េចហាស

ក៖ ពាក់ស្បែកជើងអីគេស្បែងជើងផ្ទាត់យើងធម្មតានឹងហោស?

ខ៖ ពាក់ស្បែកជើងផ្ទាត់យើងនឹងហាស

ក៖ អូ៎!!បាទតាបាទ?

ខ៖
កាលពីមុននឹងអត់ដឹងទេក្មួយពាក់លើកជើងទៅធូន់ជើងហាសណាស់ឥឡូវនឹងអត់ទេណាស់

ក៖ បាទ!!តាបាទ?

ខ៖ វារៀងគ្រាន់បើជាងមុនហេនរណាមិនដឹងថាចាស់យ៉ាប់ណាស់ក្មួយអើយ

ក៖ អ្ហូ!!ចឹងទេ?

ខ៖ ដូចគេថាចឹងហាសឃើញគេអាយុ35ឆ្នាំអីនឹងឃើញគេច្រត់ក្បាលជង្គង់អីនឹងហាសក្មួយ

ក៖ ចឹងមានន័យថាគេក៏ឈឺដែរ?

ខ៖

អើរៗៗយកចង្ហាន់ទៅបង្គេនលោកសុទ្ធតែច្រត់ក្បាលជង្គង់នឹងតែក្បែរ40ឆ្នាំអីវិនថាកុងអីនឹង គ្រាន់បើតិចខ្ញុំនឹងហាសថាកុងហាស

ក៖ បាទ!!តាបាទ?

ខ៖ អើរយ៉ាប់ណាស់ក្មួយអើយចាស់មិនងាយទេ

ក៖ បាទ!!ចុះតាគិតថាតាចូលចិត្តពិសារម្ហូបអីគេដែរតា?

ខ៖ ថ្ងៃណាជួនណាត្រីចឹងទៅ ជួនណាសាច់ជ្រូកចឹងទៅនឹងត្រីសមុទ្រចឹងទៅ

ក៖ ប៉ុន្តែបើនិយាយពីមុខម្ហូបដែរតាចូលចិត្តវិញហាស ដូចជាថាស្ងោរ ឆា ចៀនអីវិញចឹងហាស?

ខ៖ ណែតាសំលម្ជូរសាច់គោនឹងតាចូលចិត្តដែរនឹង

ក៖ ស្លម្ជូរសាច់គោនឹងហោសតា?

ខ៖ អើរៗៗនឹងហើយ

ក៖ ម្ជូរគ្រឿងហីតាហី?

ខ៖ អើរម្ជូរគ្រឿងអីនឹង

ក៖ អ្ហូ!!បាទតាបាទ?

ខ៖ ប៉ុន្តែសាច់ជ្រូកនឹងអីអត់សូវទេណាស់អត់សូវឃ្លានប្រាប់ត្រង់តែម្តងនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ ទេមិនសូវចំណូលទេតែបើសាច់គោនឹងបានហាសហូបបានវិញ

កៈ ចុះតាគិតថាកាលពីក្មេងនឹងតាធ្លាប់លេងល្បែងប្រជាប្រិយ៍អីទេតា?

ខៈ អត់អត់ទេនឹងហាសក្មួយអត់ទេ

កៈ ដូចថាចោលឈូង លាក់កន្សែងអីដែរទេ?

ខៈ បើថាចោលឈូងចោលអីនឹងធ្លាប់លេងនឹងហោស
បើថារឿងបៀរអាប៉ោងអីនឹងអត់ទេចំណាស់នឹងហើយនឹង

កៈ អត់ទេចង់និយាយថាចោលឈូង លាក់កន្សែងបោះអង្គុញអីចឹង?

ខៈ ខ្ញុំលេងអានឹងខ្ញុំលេង

កៈ ចុះតាលេងនៅណាវិញតា?

ខៈ លេងនៅវត្តចឹងទៅ

កៈ អូ៎!!ដូចថាលេងនៅវត្តចឹងទៅណាតា?

ខៈ អូ៎!!លេងលេងនៅវត្តអីនឹងដូចថាចូលឆ្នាំអីនឹងលេងនៅវត្តអីនឹងចឹងទៅណាស់

កៈ បាទ!!តាបាទ?

ខៈ លេងកាលនៅក្មេងៗៗនឹងតែឥឡូវនឹងចាស់ហើយអត់លេងទេ

កៈ ប៉ុន្តែភាគច្រើនលេងជាមួយមិត្តភក្តិណាតាណា?

ខៈ អើរនឹងហើយសប្បាយដែរនឹងសប្បាយណាស់

កៈ អូ៎!!ប៉ុន្តែតាចេះច្រៀងអត់តា?

ខៈ អត់ទេអត់ទេៗៗអត់ចេះទេ

កៈ ប៉ុន្តែតាចូលចិត្តស្តាប់បទចំរៀងទេចឹង?

ខៈ អើរបើបទចំរៀងនឹងចឹមិនស្តាប់បើបទចំរៀងនឹងចេះស្តាប់តាអត់ចេះច្រៀងទេ

កៈ លក្ខណៈជាបទបុរាណរឺមួយក៏បទសម័យដែរតាចូលចិត្តស្តាប់ដែរតា?

ខ៖ អូ៎!!ចូលចិត្តស្តាប់នឹងបទបុរាណបទអីនឹងហាសចូលចិត្តស្តាប់ហើយនឹងហាស សម័យក៏ចូលចិត្តដែរក្មួយ

ក៖ ចឹងហោសតា?

ខ៖ អើរនឹងហើយ

ក៖ ប៉ុន្តែតាគិតថាអើរលក្ខណះថាជាស្តាប់ធិមអីនឹងតាចូលចិត្តស្តាប់អត់?

ខ៖ កាលពីមុនចូលចិត្តស្តាប់ណាស់ក្មួយអើយ

ក៖ អូ៎!!ចឹងណាតាហោស?

ខ៖ អើរបើរឿងធិមអារ្យអីនឹងតាចង់ចេះណាស់នឹងតែរៀនមិនសូវជាចាំ

ក៖ អូ៎!!ចុះតាគិតថា?

ខ៖

តែឥឡូវនឹងចាស់អត់ទេណាស់អូនដល់ពេលចាស់ចឹងទៅរៀនភ្លេចមុខភ្លេចក្រោយហើយនឹង មិនដូចក្មេងណា

ក៖ ចុះតាគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសារមាននរណាគេមួយចេះលេង ឧបករណ៍ភ្លេងដែរទេតា?

ខ៖ ដូចជាអត់មានទេឪៗៗនឹងដូចជាអត់មានទេ

ក៖ លក្ខណះថាភ្លេងខ្មែរ ភ្លេងពិនពាត ភ្លេងសៀម រឺមួយក៏អកកណ្តុងអីចឹងហាស?

ខ៖ អានឹងគេមាននៅស្រុកអ៊ុំថីមិនមាន

ក៖ ប៉ុន្តែបងប្អូនរបស់តាមានអត់?

ខ៖ អត់មានទេ

ក៖ អត់មានទេណាតា?

ខ៖ មានតែគេនៅក្បែរៗៗក្មួយៗៗនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ មានតែក្មួយអ៊ុំបង្កើតទេមានតែនៅជិតគ្នានឹងហាស

ក៖ បាទ!!

ខ៖ អើរអានឹងគេមានលេងហាស

ក៖ ចុះផ្ទះរបស់តាមានលក្ខណៈបែបណាដែរតាតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ ផ្ទះកាលយើងពីតូចអាមុនពីមុនផ្ទះតូចអូនណាស់

ក៖ អូ៎!!

ខ៖ ដល់ពេលឥឡូវនឹងយើងមកធ្វើផ្ទះធំចឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ ឥឡូវនឹងផ្ទះរបស់អ៊ុំវាធ្វើបាក់បែកអស់ហើយនឹងហាស
មករុះធ្វើផ្ទះតូចនៅផ្ទះកាតាំងនៅផ្ទះមួយខ្នងវិញចឹងហាសចុះវាបាក់ហើយវាទ្រេតហាសរុះចេញអស់ហើយនឹងហាស

ក៖ ចុះការពីក្មេងនឹងផ្ទះយ៉ាងម៉េចដែរតា?

ខ៖ កាលពីក្មេងនឹងផ្ទះស្លឹកយើងនឹង

ក៖ ផ្ទះស្លឹកទេណោះតា?

ខ៖ អើរផ្ទះស្លឹកផ្ទះចិនបិទដីនឹងហាស

ក៖ អូ៎!!បាទតាបាទ?

ខ៖ អូនគេបិទដីអាដីដំបូកហាស

ក៖ ចុះដល់ពេលដែរផ្ទះឥឡូវនឹងផ្ទះយ៉ាងម៉េចដែរតា?

ខ៖ ឥឡូវនឹងធ្វើផ្ទះអើរខ្មែរ

ក៖ ផ្ទះខ្មែរណាតា?

ខ៖ បាទៗ!!

កះ ប៉ុន្តែដូចជា?

ខះ ផ្ទះកាតាំងមួយខ្ទងនឹងហាស

កះ បាទ!!ចុះផ្ទះមួយនឹងដូចជានរណាគេជាអ្នកជូសជុលវាដែរតា?

ខះ នៅយាយណែឥឡូវនឹងនៅកូនចៅ

កះ ប៉ុន្តែនរណាគេជាអ្នកធ្វើផ្ទះមួយនឹងដែរតា?

ខះ កូនៗៗ

កះ អូ៎!!កូនៗៗណាតា?

ខះ បាទ!!កូនៗៗនៅតែខ្ញុំ

កះ ប៉ុន្តែបងប្អូនរឺមួយក៏កូនចៅរបស់តាមាននរណាគេចេះធ្វើផ្ទះទេតា?

ខះ អត់អត់មានទេ

កះ អត់មានចឹងយើងជួលគេធ្វើណាតា?

ខះ ជួលគេធ្វើនឹងហាសអត់មានទេជួលគេធ្វើនឹងហាសជួលគេនឹង

កះ អូ៎!!ចុះតាគិតថាតាមានជំនាញអីដែរតាគិតថាតាចេះស្ទាត់ជំនាញដែរទេតា?

ខះ អត់ទេអូនអត់ទេគ្មានជំនាញអីទេជំនាញតែធ្វើស្រែធ្វើភ្លឺនឹង

កះ ជំនាញតែធ្វើស្រែនឹងហោសតា?

ខះ មានតែប៉ុណ្ណឹង

កះ ចុះតាគិតថាឪពុកម្តាយរបស់តាធ្លាប់បង្រៀនពីជំនាញអីទៅតាដែរទេ?

ខះ គាត់ណែកាលពីដើមនឹងឪពុករបស់តាគាត់បួសដែរនឹងហាស

កះ អូ៎!!ចឹងហោសតា?

ខះ គាត់បួសរៀនដែរនឹងហាស

កៈ ចុះតាអាចប្រាប់ពីពេលដែរលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះបានដែរទេតា ដូចថាតាមានការលំបាកអីគេខ្លះដែរចឹងហាស?

ខៈ អ៎ូ!!ពិបាករែកនេះរែកនោះរៀបរាប់ប្រាប់អូនឯងពេលមុននឹងហាស រៀបធ្វើនេះធ្វើនោះចឹងពិបាកហាសណាស់

កៈ បាទ!!ចុះ?

ខៈ ទៅធ្វើការងារខ្ញុំគេអីទៅក្មួយហាស

កៈ ចុះនៅជំនាន់អឺសាវ៉ាក់តាគិតថាតាមានការលំបាកអីគេខ្លះដែរទៅតា?

ខៈ អត់ទេនៅជំនាញអឺសាវ៉ាក់អត់មានទេតានៅតូចៗៗនឹងហាស

កៈ នៅតូចៗៗណាតារហូតដល់ជំនាន់យាគកុង?

ខៈ តានៅជំទង់ៗៗនឹងហាសអាជំនាន់យាគកុងនឹងអានឹងតាការហើយអស់ហើយនឹងហាស ការហើយយូរហើយនឹងហាសអានឹងយាគកុងនឹងហាស

កៈ ប៉ុន្តែពេលណុងពួកយាគកុងនឹងគេអោយតាធ្វើអីគេខ្លះដែរទៅតា?

ខៈ យាគកុងនឹងបានហើយរត់ចេញពីភូមិអស់ហើយនឹងហាស

កៈ យើងនាំគ្នារត់ចេញពីភូមិហោសតា?

ខៈ អើរនៅស្រុកគេនៅឯស្រុកលើនេះនឹង

កៈ បាទ!!តាបាទ?

ខៈ ហើយនៅអាណៃកុងព្រំដែននឹងគេនាំគ្នារត់ចោលអស់ហើយគ្មាននៅទេ

កៈ បាទ!!បាទៗៗ?

ខៈ រត់មកលើអស់ហើយនឹង

កៈ ចុះតាគិតថាកាលពីនៅជំនាន់លុនណុលវិញអានឹងតាមានការលំបាកអីគេខ្លះដែរទៅតា?

ខ៖
ទេអានឹងណៃពេលលុនណុលនឹងអានឹងគេរត់មួយសារហើយនឹងធ្លាយមកស្រុកគេអស់ហើយនឹង

ក៖ បាទ!!តាបាទ?

ខ៖ រត់មកនៅលើអស់ហើយនឹងហាសមានគ្រាប់នៅជំនាន់លុនណុលនឹងហាស

ក៖ បាទ!!តាប៉ុន្តែពេលណុងគេមានចាប់ធ្វើជាទាហ៊ានអីអត់តា?

ខ៖
កាលនៅជំនាន់សង្គមលុនណុលគេអត់មានចាប់ធ្វើជាទាហ៊ានអីទេដូចជាអត់មានទេអត់ចាប់ទេ ចាស់ៗៗអត់

ក៖ ប៉ុន្តែពេលណុងមានគ្រាប់ផ្លោងមានអីដែរណាតា?

ខ៖ ថីមិនមាន

ក៖ ចឹងយើងរត់ហើយណា?

ខ៖ មានឡានអាប៉េគ្រាប់ផ្លោងអីនឹង

ក៖ យើងរត់ពេញនឹងហើយណាតា?

ខ៖
អើររត់មកលើអស់ហើយកុងរត់មកលើអស់ហើយនឹងហាសចោលភូមិអស់ហើយនឹងហាស

ក៖ រត់មកលើនឹងរត់ទៅណាវិញដែរតា?

ខ៖ ទៅមកគេហៅស្រុកដងទុង ស្រុកឈូកអីវិញទៅណាស់

ក៖ អ៎ូ!!នៅខេត្តកំពតដែរហោស?

ខ៖ អានឹងនៅខេត្តកំពតនឹងដែរខេត្តកំពតដូចតែគ្នានឹងហាស

ក៖ អ៎ូ!!បាទតាបាទ?

ខ៖
មកនៅលើនឹងហាសកាលជំនាន់អ៊ីនឹងរត់ចោលអស់ហើយនឹងតាកុងហាសរត់ចោលស្រុក
អស់ហើយ នឹងគ្មាននរណាគេនៅទេនឹងហាស

ក៖ ចុះតាគិតថាកាលពីជំនាន់ពលពតនឹងតាមានធ្លាប់ជួបការលំបាកអីគេខ្លះដែរទៅតា?

ខ៖ កាលជំនាន់អាពតនឹងវែកតែបន្លែនឹង

ក៖ វែកបន្លែហោសតា?

ខ៖ វែកបន្លែនឹងហាស

ក៖ ប៉ុន្តែពេលណុងតាគេអោយ?

ខ៖ មើលវែកបន្លែចប់ហើយគេចាប់អោយដឹកបន្លែ ដឹកបន្លែសេដ្ឋកិច្ចហាសណាស់

ក៖ បាទ!!តាបាទ?

ខ៖ ដឹកបន្លែដឹកអង្ករអោយគេដាក់ធ្វើបន្លាយអោយគេធ្វើទំនុបនឹងហាសយើងដឹកអោយគេ

ក៖ បាទ!!តាប៉ុន្តែពេលនឹងតាទៅណាគេចាប់តាទៅណា?

ខ៖ អត់មានអត់ទេ

ក៖ តានៅស្រុកណុងហោស?

ខ៖
គេអត់ចាប់តាទៅណាទេគេប្រជុំតាចំតានឹងតាយិតវិញនឹងកាលពីជំនាន់ណុងហាសតាមិន
សូវខ្លាច
ដែរនឹងហាសតាធ្វើអោយស្លាប់ណាវាមិនខឹងតាគេហៅទៅប្រជុំពីរបីដងដែរនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖
ប្រជុំពីរបីដងដែរនឹងហាសតាដោះស្រាយនិយាយគ្នាទាល់ភ្លឺមិនមែនតែតាម្នាក់ទេណាស់

ក៖ តាតវ៉ាដែរណេតា?

ខ៖
អ៊ូ!!តាសួរឆ្លើយទៅខ្លាចអីនិយាយឥឡូវនឹងមានសិទ្ធិដូចគ្នានិយាយទៅតវិញថាមិនធ្វើម៉េច
វាធ្វើថា ឯងវាមិនធ្វើអាគណៈកងនឹងដើរចង្កុលលិចចង្កុលកើតនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ ហើយកាលជំនាន់ណុងបើធ្វើៗៗទាល់ស្លាប់នឹងហាស

ក៖ បាទ!!ប៉ុន្តែកាលពីជំនាន់ណុងតាអាយុប៉ុន្មានដែរហើយតា?

ខ៖
ហោ៎!!ជំនាន់ណុងអាយុប៉ុន្មានទេអូនអើយកាលណុងកូនៗៗនឹងនៅជំទង់ៗៗអត់ទាន់កំ
លោះក្រមុំ អត់ទាន់ធំៗៗទេណាស់

ក៖ ប៉ុន្តែពេលណុងគេអោយតាទៅធ្វើនឹងលក្ខណៈនៅជាមួយក្រុមគ្រួសាររឺ
កូនចៅតាតែម្តងរឺមួយក៏អត់ទេ?

ខ៖
អត់ទេធ្វើនឹងណៃកូនចៅបែកអស់ហើយណាស់អត់មានអោយដេកជាមួយម៉ែឪទេណាស់

ក៖ បាទ!!

ខ៖ ជាមួយបងថាអាយុ50ឆ្នាំជាងនឹងហាសអានឹងកងកុមារហើយណាស់

ក៖ បាទ!!តាបាទ?

ខ៖
អត់អោយនៅជិតម៉ែឪអត់អោយនៅជួបម៉ែឪផងនឹងពួកនឹងមិនអោយទៅជួបផងអាកងកុមា
រទៅ ច្រូតកន្ត្រាំងខែតនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ មិនអោយមកជួបម៉ែទេណាស់កាលណុងហាស

ក៖ ចុះអើរពេលណុងប្រពន្ធតាគេអោយធ្វើអីគេដែរទៅ?

ខ៖ ណៃនីសណៃធ្វើស្រែ

ក៖ ធ្វើស្រែហោសតាប៉ុន្តែគេអត់អោយនៅជាមួយតាទេណា?

ខ៖ អត់ទេគេអោយនៅជាមួយគ្នា

ក៖ នៅជាមួយគ្នាហោស?

ខ៖ នៅជាមួយគ្នាតែកូនអត់មាននរណាគេនៅជាមួយមួយទេ

ក៖ ប៉ុន្តែធ្វើការងាររៀងខ្លួន?

ខ៖ រៀងខ្លួនឥឡូវនឹងដូចថាកុងទៅភ្ជួរស្រែព្រឹកចឹងហាសណាស់

ក៖ បាទ!!

ខ៖ ហើយយាយនឹងគាត់ដកសំណាបចឹងហាសណាស់

ក៖ អូ៎!!ចឹងហោសតា?

ខ៖ បាទ!!អានឹងវាចឹងហាសណាស់

ក៖ ប៉ុន្តែដូចជា?

ខ៖
ហើយបើយើងណែយប់ចឹងនៅជាមួយផ្ទះនឹងគ្នាទេណាស់ហើយបើថាកូនអត់បាននៅទេ
ឥឡូវនឹងកូនបងរបស់អ៊ុំនឹងពិបាកចង់ស្លាប់ហើយណាស់
កាលពីជំនាន់អាពតនឹងហាសគេមិនអោយជួប ផងតែនឹកម៉ែឪ

ក៖ អូ៎!!ចឹងហោសតា?

ខ៖ ហីកាលពីជំនាន់ណុងហាសគេអត់អោយទៅជួបទេណាស់គេទៅតាមហាស

ក៖ គេមកតាមមើលយើងហោសតា?

ខ៖ រត់មកផ្ទះយំនឹងគេមកតាមដល់ផ្ទះហាសណាស់គណះកងគេនឹងហាស

ក៖ បាទ!!តាបាទ?

ខ៖ អូ៎!!អត់បានទេជំនាន់ណុង

ក៖ សាហាវហោសណតា?

ខ៖
អូ៎!!សាហាវណាស់ហើយមិនដឹងថាបាយទឹកនៅណាទេអាខ្លះងាប់អត់បាយអីវិននឹងហាស

ក៖ ចុះរបបអាហារយ៉ាងម៉េចដែរតា?

ខ៖
អូ៎!!ពិបាកនិយាយណាស់អើរពិបាកនិយាយណាស់មានតែច្រូតអង្ករបានច្រើននឹងមិនដឹងថាបាត់ ទៅណាអស់ទេនឹង

ក៖ អូ៎!!បាទតាចុះ?

ខ៖ តែបាត់អស់ហើយនឹង

ក៖
ចុះតាគិតថាចឹងមានន័យថាតាំងពីពលពតរហូតទាល់តែចប់គឺតាធ្វើតែនៅណុងរហូតនឹង?

ខ៖ អើរធ្វើតែចឹងរហូតនឹង

ក៖ ជាមួយក្រុមគ្រួសាររបស់តាចឹងទៅ?

ខ៖
អើរជាមួយគ្រួសាររហូតតតឡូវនឹងហើយតឡូវនឹងយាយរបស់ខ្ញុំនឹងចូលជិត80ឆ្នាំហើយណាស់ បងខ្ញុំប៉ុន្មានឆ្នាំហើយណាស់ចូល75ឆ្នាំហើយណាស់

ក៖ អូ៎!!យាយបងតាវិញហោស?

ខ៖ បងខ្ញុំប៉ុន្មានឆ្នាំដូចជា4ឆ្នាំអីនឹងហាស

ក៖ ប៉ុន្តែតឡូវនឹងយាយនៅរស់ទេ?

ខ៖ នៅគាត់នៅរស់នឹង

ក៖ ប៉ុន្តែគាត់នៅស្រុកហោសតា?

ខ៖ អត់ធ្វើអីទេនៅផ្ទះនឹងនៅស្រុក

ក៖ អូ៎!!

ខ៖ អត់មានធ្វើអីទេពីព្រោះកូនចៅចិញ្ចឹមចុះចាស់ៗៗអស់ហើយនឹងហាស

ក៖ គាត់ចិញ្ចឹមវិញហើយណតាណា?

ខ៖ អើវាចិញ្ចឹមវិញហើយនឹង

ក៖ អ៎ូ!!បាទតាបាទ?

ខ៖ នឹងហើយឥឡូវនឹងពិបាកតាំងពីក្មេងនឹងពិបាកឆ្អែតហើយក្មួយអើយ

ក៖ បាទ!!តាចុះតាគិតថាដាច់ពលពតតាមានការលំបាកអីផ្សេង
ដោយសារតែដាច់ពលពតនឹងយើងមាន ការលំបាកម្តងទៀតហើយណតា?

ខ៖ អើរអានឹងលំបាកនឹង

ក៖ រកលុយរកអី?

ខ៖ ត្រូវរកលុយចិញ្ចឹមកូនរកចិញ្ចឹមកូនហាស

ក៖ បាទ!!បាទតាបាទ?

ខ៖
លំបាកណាស់ល្មមបានកូនធំៗហើយនឹងហើយកូនធំនឹងការកូននឹងរឹតតែអស់មាំទៀតហាស ចុះមានកូន6នាក់ហោសច្រើនហាសណាស់

ក៖ បាទ!!តាបាទ?

ខ៖ ចុះអ្នកខ្លះការពីរដងអីវិននឹងហាស

ក៖ អ៎ូ!!ចឹងហោសតា?

ខ៖ ហ៎ា!!ចុះអ្នកខ្លះលែងគ្នាហោសការគេអូយ៉ាប់ហាសក្មួយអើយថាម៉ែឪថាស្រួលហាស

ក៖ អ៎ូ!!បាទចុះតាគិតថាតាឆ្លងកាត់ការលំបាកទាំងអស់នឹងដោយរបៀបណាដែរតា
ការលំបាកដែរតារៀបរាប់ប្រាប់ខ្ញុំម៉េចចឹងហាស តាឆ្លងកាត់វាម៉េចទៅ?

ខ៖ និយាយទៅពិបាកនិយាយណាស់ក្មួយពិបាកនិយាយមាំណាស់

ក៖ អស់អីនិយាយតែម្តងហោសតា?

ខ៖ អស់អីនិយាយតែម្តងនឹងនិយាយអោយចប់ទៅអស់អីនិយាយហើយ

ក៖ បាទ!!ចុះតាគិតថាពេលណាដែរតាគិតថាតាសប្បាយហាស
តាចាប់ផ្តើមសប្បាយហាសតា?

ខ៖ ឥឡូវនឹងសប្បាយឥឡូវនឹងហាសជំនាន់ឥឡូវនឹងក្មេងឥឡូវនឹងគេសប្បាយហើយ
ចាស់ៗៗហួសដេឡេហើយនឹង

ក៖ អូ៎!!បាទតា
ចុះតាគិតថាកាលពីក្មេងនឹងតាធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងតាចង់ធ្វើអីដែរទេ?

ខ៖ អត់មានធ្វើអីទេ

ក៖ តាគិតថាតាចង់?

ខ៖ ចង់តែរៀនសូត្រតែអត់បានរៀនសូត្រស្តាយងាប់ហើយ

ក៖ ប៉ុន្តែតាគិតលក្ខណះថាចង់ធ្វើជាប៉ូលីស ធ្វើទាហ៊ានធ្វើពេទ្យធ្វើគ្រូអីទេ?

ខ៖ អត់ទេអត់ទេ

ក៖ អត់ដែរចង់ទេណាតា?

ខ៖ អត់ទេអូនអត់ទេ

ក៖ ចុះបើសិនជាចង់អោយតាផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗរបស់តា
តើតាចង់ផ្តែផ្តាំអីទៅពួកគាត់ដែរតា?

ខ៖
អានឹងបើកូនចៅវាចង់បានធ្វើការងារអស់ហើយពិបាកតែយើងវាអត់ខ្សែរយះអត់ពិបាកណាស់

ក៖ បាទ!!តា?

ខ៖ ក្មេងសារក្រោយនឹង

ក៖ ចុះបើតាចង់អោយគាត់ជៀសវៀងវិញតើតាចង់អោយពួកគាត់ជៀសវៀងអីគេដែរ?

ខ៖
ឥឡូវនឹងធ្វើអីបើមានប្រពន្ធមានកូនខ្លះហើយមានចៅរិនហើយនឹងកូនៗៗកុងនឹងហាស

ក៖
អូ៎!!បាទចុះបើសិនជាចង់អោយគាត់ជៀសវៀងកូនចៅរបស់តាហាសចង់អោយពួកគាត់ជៀសវៀង ពីអីគេដែរតាពីអំពើឆក់ប្លន់អីចឹងទៅណាស់?

ខ៖ អត់មានទេអត់កូនចៅការសុទ្ធតែរកស៊ីអស់

ក៖ អូ៎!!បាទតាបាទ?

ខ៖ រកស៊ីអាខ្លះធ្វើអេតចាយចឹងទៅ

ក៖ និយាយទៅពួកគាត់ធ្វើអាចារ្យដែរហោសតា?

ខ៖ អើរកូនតាអាខ្លះធ្វើអាចារ្យដែរចឹងទៅណាស់

ក៖ គាត់ធ្វើនៅណាគាត់ធ្វើនៅណុងហោសតា?

ខ៖ អើរគាត់ធ្វើនៅនោះនៅស្រុកនឹង

ក៖ អូ៎!!ចឹង?

ខ៖ អត់មាននរណាកូនចៅតាអត់មាននរណារកស៊ីលួចប្លន់នរណាគេទេ

ក៖
អត់ទេចង់និយាយថាអោយពួកគាត់ជៀសវៀងហាសកុំអោយពួកគាត់ធ្វើអំពើមួយនឹងអីចឹងហាស?

ខ៖ អត់ទេអត់ទេៗៗ

ក៖ ចុះលក្ខណះជក់គ្រឿងញៀនអីចឹង?

ខ៖ អូ៎!!អានឹងអត់ទេក្មួយអត់ទេ

ក៖ អានឹងការពារហើយណតា?

ខ៖ អត់មានទេ

កៈ អូ៎!!បាទតា?

ខៈ អត់មានទេកូនចៅកុងនឹងគ្មានទេសុទ្ធតែអ្នកបួសរៀនចេះដឹងគ្មានទេ

កៈ បាទ!!តាចុះបើសិនជាតាមានអីដែរចង់ផ្ដែផ្ដាំអីផ្សេងពីនឹងទៀតអត់តា?

ខៈ អត់មានស្អីទៀតទេអូនអស់ហើយនឹងចប់

កៈ ចឹងមានតែប៉ុណ្ណឹងទេហោសតា?

ខៈ អស់ហើយចប់នឹង

កៈ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនតាដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់តា?

ខៈ បាទៗៗ!!ចឹងហោស

កៈ
ហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយតា ចឹងហាសតា?

ខៈ បាទ!!ចឹងហោស

កៈ ចឹងអរគុណច្រើនតា៕៕៕